## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ កម្មករនិយោជិតតាមរោងចក្រ សហគ្រាស និងកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ ( ស៊ីណូវ៉ាក់ ) ដូសទី១ និងដូសទី២ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សូមជម្រាបជូន សាធារណជន អំពីលទ្ធផលការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី១ និងដូសទី២ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ចាប់ពីថ្ងៃទី៧ ខែមេសា ដល់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១ ដូចខាងក្រោម៖

### ក-ការចាក់វ៉ាក់សាំងដូសទី១

- **លទ្ធផលក្នុងថ្ងៃទី១ ខែឧសភា**
  - អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ៨៥៦នាក់ (បរទេសចំនួន ១១នាក់)
  - ចាក់បានចំនួន ៨៣៧នាក់ (បរទេសចំនួន ១១នាក់)
  - គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ១៩នាក់ (បរទេសចំនួន ០នាក់)
- **លទ្ធផលគិតត្រឹមថ្ងៃនេះ**
  - អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ១២៥ ៣៤៦នាក់ (បរទេសចំនួន ៣ ៩៨០នាក់)
  - ចាក់បានចំនួន ១២២ ១៣៤នាក់ (បរទេសចំនួន ៣ ៩៥៩នាក់)
  - គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៣ ២១២នាក់ (បរទេសចំនួន ២១នាក់)

### ខ-ការចាក់វ៉ាក់សាំងដូសទី២

- **លទ្ធផលក្នុងថ្ងៃទី១ ខែឧសភា**
  - ចាក់បានចំនួន ៨ ៦៦០នាក់ (បរទេសចំនួន ២៥៦នាក់)
- **លទ្ធផលគិតត្រឹមថ្ងៃនេះ**
  - ចាក់បានចំនួន ៤៥ ៥៣១នាក់ (បរទេសចំនួន ១ ៥៨៨នាក់)

អនុគណៈកម្មការចំពោះកិច្ច នឹងបន្តរៀបចំទីតាំងចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ជាបន្តបន្ទាប់ទៀត។

អាស្រ័យហេតុនេះ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសៅរ៍ ៥រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១